**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ ១២/១៥ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៥

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំអង្គការចាត់តាំងគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស និងតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស

**យោង**: - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា

- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៥
- មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការរៀបចំអង្គការចាត់តាំងគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស និងតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេសដូចខាងក្រោម :

## I- គោលការណ៍បង្កើតអង្គការចាត់តាំងគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស

១- នៅប្រទេសដែលមានស្ថានតំណាងបេសកកម្មការទូតនៃព្រះរាជាណាចក្រកម្ពុជា បើមានសមាជិកគណបក្សប្រជាជនកម្ពុជាយ៉ាងតិច ៣នាក់ ត្រូវបង្កើតសាខាគណបក្ស ហើយបន្តកសាង ពង្រីកសមាជិក និងអង្គការចាត់តាំងគណបក្សឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីបង្កើតគណៈកម្មាធិការគណបក្ស ។

២- នៅប្រទេសដែលមានសមាជិកគណបក្សប្រជាជនកម្ពុជាចាប់ពី ៥០នាក់ ឡើងទៅ ហើយមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវបង្កើតគណៈកម្មាធិការគណបក្ស ។ បើមានសមាជិកគណបក្សតិចជាង ៥០នាក់ ឬក្នុងដំណាក់កាលដំបូង ដែលមិនទាន់មានអង្គការចាត់តាំងគណបក្ស ត្រូវបង្កើតសាខាគណបក្ស ឬគណៈកម្មាធិការសាខាគណបក្ស ។

៣- រចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស នាដំណាក់កាលបច្ចុប្បន្នត្រូវបានរៀបចំឲ្យមាន :

- គណៈកម្មាធិការគណបក្សប្រចាំសហរដ្ឋ សហព័ន្ធ ឬប្រចាំប្រទេស ។
- គណៈកម្មាធិការសាខាគណបក្សប្រចាំរដ្ឋ ឬប្រចាំតំបន់ ទីក្រុង ទីប្រជុំជនសំខាន់ៗ ដែលមានសហគមន៍ខ្មែររស់នៅច្រើន ។
- អនុសាខាគណបក្សចំណុះតាមការចាំបាច់ ។

៤- គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស អាចកសាងពង្រីកសមាជិកគណបក្ស និងបង្កើតសាខាគណបក្ស ឬគណៈកម្មាធិការសាខាគណបក្សប្រចាំនៅប្រទេសជិតខាងមួយទៀតក្នុងតំបន់ តាមការប្រគល់ភារកិច្ចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។ នៅពេលដែលសាខាគណបក្សប្រចាំនៅប្រទេសនោះមានការរីកចម្រើនអាចបង្កើតបានច្រើនសាខាគណបក្សផ្សេងទៀត ហើយមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវពិនិត្យរៀបចំបង្កើតគណៈកម្មាធិការគណបក្សប្រចាំប្រទេស ដោយបំបែកចេញពីគណៈកម្មាធិការគណបក្សដែលគ្រប់គ្រងដឹកនាំពីមុនមក ។

៥- សមាសភាពនៃគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេសត្រូវបានពិនិត្យសម្រេចដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

សមាសភាពនៃគណៈកម្មាធិការសាខាគណបក្ស និងអនុសាខាគណបក្សចំណុះ ត្រូវបានពិនិត្យសម្រេចដោយគណៈកម្មាធិការគណបក្សប្រចាំសហរដ្ឋ សហព័ន្ធ ឬប្រចាំប្រទេស ។ ដោយឡែកចំពោះកន្លែងណាដែលមិនទាន់បានបង្កើតគណៈកម្មាធិការគណបក្ស គឺគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ពិនិត្យសម្រេចអំពីសមាសភាពនៃគណៈកម្មាធិការសាខាគណបក្សប្រចាំប្រទេស ។

៦- គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស មានត្រាសម្រាប់ប្រើប្រាស់ក្នុងការងារគណបក្ស ។

## II- **<u>តួនាទី ភារកិច្ច សិទ្ធិ របស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស</u>**

### **ក- <u>អំពីតួនាទី</u>**

គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ស្ថិតក្រោមការដឹកនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ដោយមានគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជាជំនួយការ ។ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អាចប្រគល់ភារកិច្ចដឹកនាំនេះឲ្យគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុវត្តជំនួសបានស្របតាមសភាពការណ៍ជាក់ស្តែង ។

គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ទទួលខុសត្រូវចំពោះមុខគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងគណបក្សថ្នាក់ខ្លួន ក្នុងការដឹកនាំ ត្រួតពិនិត្យការអនុវត្តគ្រប់វិស័យការងាររបស់គណបក្ស ដើម្បីសម្រេចភារកិច្ចនយោបាយដែលគណបក្សថ្នាក់លើបានកំណត់ និងសេចក្តីសម្រេច

ចិត្តរបស់គណបក្សថ្នាក់ខ្លួន ។

៩- **<u>អំពីភារកិច្ច</u>**

ភារកិច្ចសំខាន់ៗ របស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេសរួមមាន :

១- ផ្អែកលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយរបស់គណបក្ស គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណៈកម្មាធិការកណ្តាល ច្បាប់បញ្ញត្តិជាធរមាន និងសេចក្តីសម្រេចចិត្តរបស់គណបក្សថ្នាក់ខ្លួន ដើម្បីកំណត់ទិសដៅ ភារកិច្ច គោលការណ៍ និងវិធានការចាត់តាំងអនុវត្ត ឲ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែង ស្របនឹងសំណូមពររបស់សហគមន៍ខ្មែរ ព្រមទាំងដឹកនាំអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួនអនុវត្តឲ្យបានសម្រេចជោគជ័យ ។

២- បំផុសលើកទឹកចិត្តដល់សមាជិកគណបក្ស និងជំរុញការងារចលនាមហាជនក្នុងសហគមន៍ខ្មែរឲ្យចូលរួមគាំទ្រ និងអនុវត្តកម្មវិធីនយោបាយ គោលការណ៍ សេចក្តីសម្រេចនានារបស់គណបក្ស ។

៣- ដឹកនាំ និងត្រួតពិនិត្យអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួនក្នុងការអនុវត្តការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង និងចលនាមហាជន ។ ទន្ទឹមនេះ ត្រូវបង្កលក្ខណៈជួយឧបត្ថម្ភដល់អង្គការ សមាគមនានា ឲ្យធ្វើសកម្មភាពបានត្រឹមត្រូវតាមតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកគាំទ្រ និងលើកកម្ពស់ប្រជាប្រិយភាពរបស់គណបក្ស ។

៤- លើកឡើងនូវគោលការណ៍ និងវិធានការដើម្បីជំរុញការងារគ្រប់គ្រង ពង្រឹងពង្រីកសមាជិកគណបក្ស សំដៅជានាបានទាំងគុណភាព និងបរិមាណ ។

៥- ត្រួតពិនិត្យសមាជិក និងអង្គការចាត់តាំងគណបក្សចំណុះក្នុងការអនុវត្តលក្ខន្តិកៈគណបក្ស គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស និងគ្រប់គ្រងហិរញ្ញវត្ថុរបស់គណៈកម្មាធិការគណបក្ស ។

៦- ចាត់តាំងផ្សព្វផ្សាយអំពីសភាពការណ៍រួម គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្ស ដល់សមាជិកគណបក្ស និងធ្វើរបាយការណ៍អំពីសភាពការណ៍ការងារគណបក្ស ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងរាយការណ៍សុំយោបល់នៅពេលមានការងារចាំបាច់ ។

៧- រៀបចំកសាងប្រព័ន្ធទំនាក់ទំនងតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាព័ត៌មាន ដើម្បីជានាការផ្លាស់ប្តូរព័ត៌មានបានឆាប់រហ័ស ទូលំទូលាយ និងមានប្រសិទ្ធភាព រវាងផ្ទៃក្នុងគណៈកម្មាធិការគណបក្ស សាខាគណបក្សចំណុះនៅក្រៅប្រទេស និងជាមួយទីស្នាក់ការកណ្តាលរបស់គណបក្សនៅក្នុងប្រទេស ។ ក្នុងករណីដែលមិនអាចកោះអញ្ជើញប្រជុំជីវភាពបក្សតាមពេលវេលាកំណត់បាន ត្រូវរៀបចំឲ្យមានកិច្ចប្រជុំ

តាមប្រព័ន្ធទូរស័ព្ទ Conference Call Service ឬ Video Conference និងការផ្ញើសារសុំយោបល់ជាលាយលក្ខណ៍អក្សរ ដើម្បីធានានូវការអនុវត្តគោលការណ៍របស់គណបក្ស "សមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ" ។

**ឆ- អំពីសិទ្ធិ**

គណៈកម្មាធិការគណបក្សនៅក្រៅប្រទេសមានសិទ្ធិ :

១- ណែនាំ និងត្រួតពិនិត្យការអនុវត្តរាល់ភារកិច្ចការងាររបស់គណបក្ស នៅក្នុងក្របខណ្ឌនៃអង្គការចាត់តាំងគណបក្សថ្នាក់ខ្លួន ។

២- សម្រេចតែងតាំង ប្រគល់ភារកិច្ច សម្រួលភារកិច្ច លើកសរសើរ និងដាក់វិន័យចំពោះមន្ត្រីគណបក្សស្ថិតក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។

៣- សម្រេចបង្កើត រំសាយ និងរៀបចំសមាសភាពដឹកនាំ នៃគណៈកម្មាធិការសាខា សាខា អនុសាខា ក្រុមបក្ស(បើមាន) និងសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ។

៤- លើកសំណើសុំសេចក្តីសម្រេចពីគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលអំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សប្រចាំសហរដ្ឋ សហព័ន្ធ ឬប្រចាំប្រទេស ។

៥- លើកសំណើសុំសេចក្តីសម្រេចពីគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការរៀបចំសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុ នៃគណៈកម្មាធិការគណបក្សថ្នាក់ខ្លួន ។

៦- លើកសំណើសុំយោបល់ពីគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការងារគណបក្សដែលមានការលំបាកស្មុគស្មាញ និងសំណូមពររបស់សមាជិកគណបក្ស ដែលគណៈកម្មាធិការគណបក្សថ្នាក់ខ្លួនមិនអាចដោះស្រាយបាន ។

III- **រចនាសម្ព័ន្ធ អង្គការចាត់តាំង របស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស**

**ក- អំពីរចនាសម្ព័ន្ធ**

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ត្រូវមានមន្ត្រីគណបក្សដែលមានតួនាទីសំខាន់ៗនៃស្ថានតំណាងបេសកកម្មការទូតរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមការងារគណបក្ស និងសមាជិកគណបក្សសកម្ម នៅក្នុងមជ្ឈដ្ឋាននានានៃសហគមន៍ខ្មែរ ដែលមានវ័យចាស់ វ័យក្មេង ស្ត្រី និងមានសុខភាពល្អ មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈគោលជំហរនយោបាយរឹងមាំ ស្មោះត្រង់ចំពោះគណបក្ស និងប្រជាជន មានឥទ្ធិពលល្អ បានទទួលការគាំទ្រពីសមាជិកគណបក្ស មានទំនាក់ទំនងល្អជាមួយមហាជន និងមានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

អំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ត្រូវពិនិត្យប្រគល់ភារកិច្ច

ជូនមន្ត្រីគណបក្សដែលមានតួនាទីខ្ពស់បំផុតនៃស្ថានតំណាងបេសកកម្មការទូតរបស់ព្រះរាជាណាចក្រកម្ពុជា ឲ្យទទួលជាប្រធានគណកម្មាធិការគណបក្ស និងជ្រើសរើសសមាជិកគណបក្សសកម្មដែលមានឥទ្ធិពលក្នុងសហគមន៍ខ្មែរជាអនុប្រធាន ។ នៅកន្លែងណាដែលអាចជ្រើសរើសសមាជិកគណបក្សសកម្មក្នុងសហគមន៍ខ្មែរជាប្រធានបាន ត្រូវពិនិត្យតែងតាំងមន្ត្រីគណបក្សដែលមានតួនាទីខ្ពស់បំផុតនៃស្ថានតំណាងបេសកកម្មការទូតជាប្រធានកិត្តិយសនៃគណៈកម្មាធិការគណបក្ស ។ ប្រធានគណៈកម្មាធិការសាខាគណបក្សចំណុះ ត្រូវបានពិនិត្យរៀបចំជាសមាជិកគណៈកម្មាធិការគណបក្ស ។

៤- **<u>អំពីបរិមាណ</u>**

បរិមាណសមាជិកគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ដែលរួមមានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិក ត្រូវបានកំណត់ដូចខាងក្រោម :

- សមាជិកគណៈកម្មាធិការគណបក្សមានចំនួន ២៣រូបចុះ ចំពោះគណបក្សដែលមានសាខាគណបក្សចំណុះចំនួន ៦ ឡើងទៅ ។

- សមាជិកគណៈកម្មាធិការគណបក្សមានចំនួន ១៧រូបចុះ ចំពោះគណបក្សដែលមានសាខាគណបក្សចំណុះចំនួន ៥ ចុះ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ ត្រូវមានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សទាំងមូល ។ ចំពោះអនុប្រធានគណៈកម្មាធិការគណបក្ស អាចរៀបចំឲ្យមានចំនួន ១រូប ឬ ២រូប ។

ដោយឡែកចំពោះគណៈកម្មាធិការសាខាគណបក្សចំណុះ ត្រូវបានកំណត់ឲ្យមានចំនួន ១១ រូបចុះ ។

**៥-** គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ត្រូវផ្អែកលើគោលការណ៍អំពីរចនាសម្ព័ន្ធ លក្ខណសម្បត្តិ សមាសភាព និងបរិមាណកំណត់ខាងលើនេះ និងផ្អែកលើសំណូមពរការងារជាក់ស្តែង ដើម្បីលើកសំណើរៀបចំគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស ឲ្យបានសមស្រប ដោយធានាបាននូវនិរន្តរភាពការងារគណបក្សនៅពេលមានការផ្លាស់ប្តូរអាណត្តិមន្ត្រី ។ គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យលើកសំណើអំពីការតែងតាំង និងសម្រួលភារកិច្ចមន្ត្រីទូត ជាប្រធាន ឬប្រធានកិត្តិយស នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ។

គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ត្រូវរៀបចំបែងចែកភារកិច្ចជូនសមាជិកម្នាក់ៗក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស ឲ្យទទួលបន្ទុកការងារគណបក្ស ជាអាទិ៍ការងារត្រួតពិនិត្យ ការងារចាត់តាំង ការងារឃោសនាអប់រំ ការងារហិរញ្ញវត្ថុ ការងារ

ចលនាមហាជន ការងារសន្តិសុខ ការងាររដ្ឋបាល និងទទួលបន្ទុកដឹកនាំកសាងពង្រឹងតាមសាខាគណបក្សចំណុះ ស្របតាមសំណូមពរភារកិច្ចជាក់ស្តែងរបស់ខ្លួន ។

IV- **របៀបរបបធ្វើការ**

**ក. គណៈកម្មាធិការគណបក្ស**

គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ដឹកនាំការងារគណបក្សថ្នាក់ខ្លួនឆ្លងតាមរយៈសន្និបាត ឬប្រជុំពេញអង្គ ១ខែម្តង ។ ការងារសំខាន់ៗដែលត្រូវដាក់ជូនគណៈកម្មាធិការគណបក្សសម្រេចរួមមាន :

១- សភាពការណ៍ ទិសដៅភារកិច្ចនយោបាយ និងវិធានការចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្ត និងគោលការណ៍របស់គណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចចិត្តនៃមហាសន្និបាតគណបក្សថ្នាក់ខ្លួន ។

២- របាយការណ៍បូកសរុប វាយតម្លៃសភាពការណ៍ការងារគណបក្ស និងទិសដៅភារកិច្ចផែនការ ប្រចាំឆមាស ប្រចាំឆ្នាំរបស់គណៈកម្មាធិការគណបក្ស ។

៣- គោលការណ៍ថ្មីៗសំខាន់ៗអំពីការងារគណបក្ស ។

៤- សំណើរៀបចំសមាសភាពគណៈកម្មាធិការគណបក្ស គណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្ស ។

៥- គោលការណ៍ និងសេចក្តីព្រាងខ្លឹមសារសម្រាប់បើកមហាសន្និបាតគណបក្សថ្នាក់ខ្លួនតាមការណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

៦- បញ្ហាផ្សេងៗ ដែលភាគច្រើននៃសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សមិនទាន់មានការឯកភាព និងឃើញថាចាំបាច់ត្រូវលើកយកមកដាក់ជូនគណៈកម្មាធិការគណបក្សសម្រេច ។

**ខ- គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស**

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ទទួលខុសត្រូវដឹកនាំការងារគណបក្ស ក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយទៀតរបស់គណៈកម្មាធិការគណបក្ស ។ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេសក្នុង ១ខែត្រូវប្រជុំ ២ដង ក្នុងករណីចាំបាច់អាចប្រជុំវិសាមញ្ញ ។

ការងាររបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេសរួមមាន :

១- ដឹកនាំ ណែនាំ ចាត់តាំងអនុវត្តសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការគណបក្សថ្នាក់ខ្លួន និងគោលការណ៍កំណត់ទាំងឡាយរបស់គណៈកម្មាធិការកណ្តាល ។

២- ដឹកនាំ ពង្រឹងអង្គការចាត់តាំងរបស់គណៈកម្មាធិការគណបក្ស គណៈកម្មាធិការសាខា និងសាខាគណបក្សចំណុះ និងណែនាំត្រួតពិនិត្យការអនុវត្តភារកិច្ចការងារគណបក្ស និងការងារចលនាមហាជន ។

៣- សហការ និងជួយឧបត្ថម្ភដល់ក្រុមការងាររបស់គណបក្ស និងអង្គការ សមាគមនៃសហគមន៍ខ្មែរ ដើម្បីបំផុសចលនាមហាជន ចូលរួមកសាងការពារសមិទ្ធផលសង្គមជាតិ និងគាំទ្រកម្មវិធីនយោបាយរបស់គណបក្ស ។

៤- សម្រេចការងាររៀបចំមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់ និងលើកសំណើរៀបចំមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

៥- ចាត់តាំងផ្សព្វផ្សាយសភាពការណ៍ ភារកិច្ចដល់គណៈកម្មាធិការគណបក្ស គណៈកម្មាធិការសាខា និងសាខាគណបក្សចំណុះ ព្រមទាំងសមាជិកគណបក្ស និងអនុវត្តរបបរាយការណ៍តាមការកំណត់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជូនគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

៦- កោះប្រជុំ និងត្រៀមរៀបចំខ្លឹមសារសន្និបាត ឬប្រជុំពេញអង្គគណៈកម្មាធិការគណបក្ស រាយការណ៍ជូនគណៈកម្មាធិការគណបក្សអំពីសភាពការណ៍ការងារដែលគណៈអចិន្ត្រៃយ៍បានសម្រេច ។

**គ- <u>ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស</u>**

១- ប្រធានគណៈកម្មាធិការគណបក្ស ជាប្រធានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ទទួលខុសត្រូវដឹកនាំរួម តាមគោលការណ៍ដែលបានសម្រេចដោយគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្ស ។

២- អនុប្រធានគណៈកម្មាធិការគណបក្ស ទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួនតាមការប្រគល់ភារកិច្ចរបស់ប្រធាន និងគណៈអចិន្ត្រៃយ៍ និងជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន ។

៣- សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស ត្រូវផ្អែកលើសេចក្តីសម្រេចចិត្ត និងគោលការណ៍នានារបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ដើម្បីដឹកនាំ ណែនាំ និងចាត់តាំងអនុវត្តនៅតាមផ្នែកការងារ និងសាខាគណបក្សចំណុះដែលខ្លួនទទួលខុសត្រូវ ។ ត្រូវកំណត់របបប្រជុំជីវភាពឲ្យបានទៀងទាត់ ក្តាប់សភាពការណ៍ និងសំណូមពររបស់មន្ត្រី សមាជិកគណបក្ស និងមហាជន ដើម្បីលើកសំណើជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស ចេញសេចក្តីសម្រេចចិត្ត គោលការណ៍ វិធានការដឹកនាំរួម ។

៤- ប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្ស ដឹកនាំការងារគណបក្សតាមស្មារតីសម្រេចនៃសមូហភាពគណៈអចិន្ត្រៃយ៍ ឬគណៈកម្មាធិការគណបក្ស ។ នៅពេលពិភាក្សាការងារ ត្រូវគោរពមតិប្រជាធិបតេយ្យ ក្រោយពេលអនុម័ត ភាគតិចត្រូវគោរពភាគច្រើន ហើយត្រូវអនុវត្តតាមគោលការណ៍ដែលសមូហភាពបានសម្រេច ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្ស កំណត់យកសំឡេងភាគច្រើនដាច់ខាតនៃសមូហភាពគណៈអចិន្ត្រៃយ៍ទាំងមូល ឬគណៈកម្មាធិការគណបក្សទាំងមូល លើកលែងតែការងារមួយចំនួនដែលមានកំណត់ដោយឡែកក្នុងលក្ខន្តិកៈគណបក្ស ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

**ជ. គណៈអចិន្ត្រៃយ៍ ៤៧.**

**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ០០១/០២២៣/ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃ ចន្ទ ៧កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

# សេចក្តីណែនាំបន្ថែម
# ស្តីពីការរៀបចំអនុប្រធានគណៈកម្មាធិការ
# គណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស

**យោង** : - សេចក្តីណែនាំលេខ ១២/១៥ សណ.គក ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៥
- សេចក្តីសម្រេចលេខ ៦៦៣/១៦ សស.គក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៦
- សំណូមពរការងារចាំបាច់
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីការរៀបចំអនុប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស ដូចខាងក្រោម៖

១-ដើម្បីធានានិរន្តរភាពការងារគណបក្សនៅពេលមានការផ្លាស់ប្តូរអាណត្តិការងាររបស់ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យ លើកសំណើអំពីការតែងតាំងនិងសម្រួលភារកិច្ចមន្ត្រីគណបក្សដែលជាអនុប្រធានស្ថានបេសកកម្មការទូតរបស់ព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលជាអនុប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស។

២- គណៈកម្មាធិការគណបក្សក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យសម្រេចតែងតាំង និងសម្រួលភារកិច្ចអនុប្រធានសាខាគណបក្សប្រជាជនកម្ពុជាប្រចាំប្រទេស (ដែលមិនទាន់បង្កើតគណៈកម្មាធិការគណបក្ស) ដើម្បីធានានិរន្តរភាពការងារគណបក្ស ស្របតាមស្មារតីដូចខាងលើនេះ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព។

**ជ.គណៈអចិន្ត្រៃយ៍**
**អនុប្រធាន**

**សាយ ឈុំ**

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល
លេខ: ៦៦៣/១៦ សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការប្រគល់ភារកិច្ចជូនគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកដឹកនាំពង្រឹងសាខាគណបក្ស និងគ្រប់គ្រង កសាងពង្រីកសមាជិកគណបក្សនៅក្រៅប្រទេស

**យោង**: - លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
- សេចក្តីណែនាំលេខ ១២/១៥ សណ.គក ចុះថ្ងៃទី ១០ ធ្នូ ឆ្នាំ ២០១៥ ស្តីពីការរៀបចំអង្គការចាត់តាំងគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស និងតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធអង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស
- សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
- សំណូមពរនៃការគ្រប់គ្រង កសាង ពង្រីកសមាជិកគណបក្សនៅក្រៅប្រទេស
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៦

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច :

**ប្រការ១** : ប្រគល់ភារកិច្ចជូនគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកដឹកនាំពង្រឹងសាខាគណបក្ស និងគ្រប់គ្រង កសាង ពង្រីកសមាជិកគណបក្ស នៅតាមបណ្តាប្រទេសដែលមិនទាន់បង្កើតគណៈកម្មាធិការគណបក្ស ។

**ប្រការ២**: គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានសិទ្ធិ :

- ណែនាំ និងត្រួតពិនិត្យការអនុវត្តរាល់ភារកិច្ចការងាររបស់សាខាគណបក្សស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។
- លើកសំណើសុំសេចក្តីសម្រេចពីគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល អំពីការបង្កើត និងតែងតាំងប្រធានសាខាគណបក្ស ។
- ពិនិត្យសម្រេចអំពីការរៀបចំសមាសភាពអនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្ស ។
- ពិនិត្យសម្រេចអំពីការរៀបចំអនុសាខាគណបក្ស និងក្រុមបក្សចំណុះសាខាគណបក្ស ។

- ពិនិត្យសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស និងផ្តល់ប័ណ្ណសម្គាល់សមាជិកគណបក្សតាមសំណើរបស់សាខាគណបក្សប្រចាំប្រទេស ។

**ប្រការ៣** : ក្រោយពេលដែលបានកសាងពង្រឹងសាខាគណបក្ស និងពង្រីកបរិមាណសមាជិកគណបក្សឲ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវរៀបចំសំណើជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលពិនិត្យសម្រេចអំពីការបង្កើត និងតែងតាំងគណៈកម្មាធិការគណបក្សប្រចាំប្រទេស ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាខាគណបក្សប្រជាជនកម្ពុជានៅតាមបណ្តាប្រទេសដែលមិនទាន់បង្កើតគណៈកម្មាធិការគណបក្សមានភារកិច្ចចាត់តាំងអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**

**អនុប្រធាន**

**សាយ ឈុំ**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

**គណៈចាត់តាំង**
លេខ : ១៥៩/១៦ បត.គក

**ភ្នំពេញ,ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៦**

# គោរពជូន
# ឯកឧត្តម ប្រធានគណៈកម្មាធិការគណបក្ស
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**កម្មវត្ថុ** : ស្តីអំពីការជំរុញការកសាងពង្រឹងសាខាគណបក្ស និងពង្រីកសមាជិកគណបក្សនៅក្រៅប្រទេស

**យោង** : -សេចក្តីណែនាំ លេខ ១២/១៥ សណ.គក ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៥
- សេចក្តីសម្រេចលេខ ៦៦៣/១៦ សស.គក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៦
- សំណូមពរនៃការកសាងពង្រឹងគណបក្សនៅក្រៅប្រទេស

តាមកម្មវត្ថុ និងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល សូមលើកឡើងនូវទម្រង់បែបបទ និងវិធានការមួយចំនួន ដើម្បីស្នើសុំ ឯកឧត្តមប្រធាន មេត្តាពិនិត្យជំរុញការកសាងពង្រឹងសាខាគណបក្ស និងពង្រីកសមាជិកគណបក្សនៅក្រៅប្រទេសដូចខាងក្រោម :

## I- អំពីការបង្កើតសាខាគណបក្សជំរុំប្រចាំប្រទេស

១- អនុវត្តតាមគោលការណ៍ "ប្រគល់ភារកិច្ចជូនមន្ត្រីគណបក្សដែលមានតួនាទីខ្ពស់បំផុតនៃស្ថានតំណាងបេសកកម្មការទូតរបស់ព្រះរាជាណាចក្រកម្ពុជា ឲ្យទទួលជាប្រធានគណៈកម្មាធិការគណបក្ស" នៅប្រទេសដែលមានស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា ហើយមានសមាជិកគណបក្សប្រជាជនកម្ពុជា ពី ៣នាក់ ឡើងទៅ សូមធ្វើសំណើរបស់គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ពិនិត្យចេញសេចក្តីសម្រេចបង្កើត និងតែងតាំងប្រធានសាខាគណបក្ស ។

២- គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួមជាមួយប្រធានសាខាគណបក្សនៅក្រៅប្រទេស បន្តពិនិត្យសម្រេចតែងតាំងបំពេញបន្ថែមអនុប្រធាន និងសមាជិកគណៈកម្មាធិការសាខាគណបក្ស និងរៀបចំអនុសាខាគណបក្ស និងក្រុមបក្សចំណុះ ។

៣- នៅពេលដែលមានការផ្លាស់ប្តូរអាណត្តិរបស់មន្ត្រីគណបក្សជាឯកអគ្គរាជទូត សូមធ្វើសំណើរបស់គណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនគណៈ

អចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ពិនិត្យចេញសេចក្តីសម្រេចសម្រួលភារកិច្ច និងតែងតាំងប្រធានសាខាគណបក្ស ឬប្រធានគណៈកម្មាធិការគណបក្ស ។

៤- សូមភ្ជាប់មកជាមួយសំណើសុំតែងតាំង នូវប្រវត្តិរូបមន្ត្រីដែលត្រូវបានស្នើសុំតែងតាំងមានបិទរូបថត ។

II- **អំពីការបញ្ចូលសមាជិកគណបក្ស**

អនុវត្តតាមខ្លឹមសារចំណុច III-៣ នៃជំនួយស្មារតី ស្តីពីការងារកសាងពង្រីកសមាជិក និងពង្រឹងអង្គការបាត់តាំងគណបក្សនៅក្រៅប្រទេស ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ ។

១- ក្រុមការងារគណបក្ស ដែលចុះធ្វើការងារឃោសនាចលនាកម្លាំងគាំទ្រគណបក្ស នៅក្នុងមជ្ឈដ្ឋានកម្មករ ពលករខ្មែរ និងមជ្ឈដ្ឋាននានានៃសហគមន៍ខ្មែររស់នៅក្រៅប្រទេស មានភារកិច្ចជួយរៀបចំទម្រង់បែបបទសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា សម្រាប់ដាក់ជូនសាខាគណបក្សពិនិត្យ ។

២- សាខាគណបក្ស ពិនិត្យសំណុំបែបបទសុំចូលជាសមាជិកគណបក្ស និងសម្រេចបញ្ចូលសមាជិកម្នាក់ៗ ហើយធ្វើបញ្ជីសមាជិកគណបក្សថ្មីនេះ រាយការណ៍ជូនគណៈកម្មាធិការគណបក្សក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យចេញសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស (នៅប្រទេសដែលមិនទាន់បង្កើតគណៈកម្មាធិការគណបក្ស) ។

៣- សាខាគណបក្ស មានភារកិច្ចរៀបចំពិធីបញ្ចូលសមាជិកគណបក្សនៅពេលវេលាសមស្រប និងត្រឹមត្រូវតាមការកំណត់នៃលក្ខន្តិកៈគណបក្ស ក្រោមអធិបតីភាព របស់តំណាងគណបក្សថ្នាក់លើ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធាន មេត្តាជ្រាប និងបាត់តាំងអនុវត្តតាមការគួរ ។

សូម ឯកឧត្តមប្រធាន ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**